**គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (គ.ប.ស.យ)**

Committee For Free And Fair Elections In Cambodia (COMFREL)

ទីស្នាក់ការកណ្តាល ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ទឹកល្អក់ ១ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

Central Office: #138, St. 122, Teuk Laak I, Tuol Kork, Phnom Penh, CAMBODIA.

P.O. Box 1145, Tel: (855) 23 884 150/12 942 019, Fax: (855) 23 883 750 E-mail: comfrel@online.com.kh, comfrel@comfrel.org or comfreladmin@online.com.kh, Site : www.comfrel.org

**ខុមហ្វ្រែល COMFREL**

**គណៈកម្មាធិការនាយក**
**BOARD OF DIRECTORS**

លោក **ធន សារាយ**
**Mr. THUN SARAY**
ប្រធានគណៈកម្មាធិការនាយក
និងជាប្រធាន **ADHOC**

លោក **សុក សំអឿន**
**Mr. SOK Sam Oeun**
អនុប្រធានគណៈកម្មាធិការនាយក
និងជានាយក **CDP**

លោក **យឹម ប៉ូ**
**Mr. YIM Po** អគ្គលេខាធិការ
និង នាយក **CCPCR**

កញ្ញា **ស៊ុន ចាន់សែន**
**Miss. SUN Chansen**
ប្រធាន **KYA**

លោក **មុំ សារិន**
**Mr. MOM Sarin**
នាយក **HRCDO**

លោកស្រី **ពឹង យក់ហៀប**
**Mr. PEUNG Yok Hiep**
នាយិកា **LAC**

លោកស្រី **ទីវ សារាយេត**
**Ms. TIV Sarayet**
សហនាយិកា **WMC**

កញ្ញា **សយ សារា វឌ្ឍនី**
**Miss. SAY Sara Vathany**
នាយិកា **CWCC**

លោក **គីម សុវណ្ណ**
**Mr. KIM Sovann**
នាយក **VIGILANCE**

លោក **អាង ច័ន្ទឫទ្ធិ**
**Mr. ANG Chanrith**
នាយក **KKKHRO**

លោក **យង់ គិមអេង**
**Mr. YONG Kim Eng**
នាយក **PDP-Center**

លោក **ភួង សិទ្ធិ**
**Mr. PHUONG Sith**

លោក **ស៊ីន សែត**
**Mr. SEN Set**

ស.ប្រ.ក.៣/លេខ ១៣/០៩ គ.ប.ស.យ/អ.ក

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី

## លទ្ធផលសិក្ខាសាលាម្ចាស់ឆ្នោតក្នុងការកំណត់លក្ខខណ្ឌសន្ទស្សន៍[១] នៃវិស័យអាទិភាពក្នុង ខេត្ត តាកែវ

*ភ្នំពេញ, ថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០០៩*

ប្រជាពលរដ្ឋប្រមាណ ៨៣នាក់ មកពីគ្រប់ស្រុក និងក្រុង ក្នុងខេត្តតាកែវក្នុងនោះមានសិក្ខាកាមស្រ្តីចូលរួមប្រមាណ៣៨% បានជួបជុំគ្នានៅក្នុងសិក្ខាសាលាម្ចាស់ឆ្នោត ក្នុងការកំណត់លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពក្នុងខេត្តតាកែវកាលពីថ្ងៃ ២២ កក្កដា ២០០៩ ដើម្បីពិភាក្សា និងកំណត់លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពក្នុងខេត្តតាកែវ ។

អភិបាលរងខេត្តតាកែវ ឯកឧត្តម **កង សំអឿន** បានថ្លែងបើកសិក្ខាសាលាថា រាជរដ្ឋាភិបាលអាណត្តិទី ៤ បានដាក់ចេញ នូវយុទ្ធសាស្រ្តចតុកោណដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាពនៅកម្ពុជា។ ឯកឧត្តមក៏បានមានប្រសាសន៍ថាយុទ្ធសាស្រ្តចតុកោណនេះបានចាត់ទុកអភិបាលកិច្ចល្អដែលផ្តោតទៅលើកំណែទំរង់ជាស្នូលនៃយុទ្ធសាស្រ្តចតុកោណ ។

អ្នកតំណាងរាស្រ្ត គួយ ប៊ុនរឿន មណ្ឌលតាកែវដែលបានទទួលលទ្ធផលនៃលក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពទាំង ១០ សំរាប់ខេត្តតាកែវដោយផ្ទាល់ដៃ បានសន្យាថានឹងពាំនាំវិស័យអាទិភាពទាំងនេះជូន និងជួយជំរុញអោយរាជរដ្ឋាភិបាលអនុវត្តលក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពទាំងនេះ។

ជាលទ្ធផលម្ចាស់ឆ្នោតបានពិភាក្សាកំណត់លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពទាំង ១០ ក្នុងខេត្តតាកែវដូចខាងក្រោម:

| |
|---|
| ១) សុំឱ្យរាជរដ្ឋាភិបាលសម្រួលអត្រាការប្រាក់ឥណទានទាបដើម្បីអោយប្រជាពលរដ្ឋខ្ចីប្រាក់យកមកប្រើប្រាស់ក្នុងវិស័យកសិកម្ម ឱ្យ មានការប្រាក់មកនៅត្រឹម១,៥% ក្នុង១ខែ ដែលបច្ចុប្បន្នការប្រាក់មានដល់ ៣%នៅក្នុងទូទាំង ខេត្ត ចាប់ពីខែសីហា ឆ្នាំ២០០៩ នេះតទៅ។ |

[១] ការសន្យាណាដែលមានសូចនាករច្បាស់លាស់-អាចមានជាក់ស្តែង អាចវាស់បានដូចជាការអនុម័តច្បាប់ ការបង្កើតស្ថាប័ន ឬជាសកម្មភាព ការអនុវត្តអ្វីមួយច្បាសលាស់ ដោយមានគោលដៅ ពេលវេលា ឬមានចំនួនកំណត់ច្បាស់លាស់ ឬមួយប្រៀបធៀបទៅនឹងអត្រាណាមួយច្បាស់លាស់។

| |
|---|
| ២) សុំអោយរាជរដ្ឋាភិបាល និងមន្ទីរកសិកម្មខេត្ត ជួយបណ្តុះបណ្តាល វិធីធ្វើជីកំប៉ុសទឹក និងកំប៉ុសគោក ដល់កសិករគ្រប់ស្រុក នៅទូទាំងខេត្តតាកែវ អោយបានមួយដងក្នុង មួយឆ្នាំចាប់ពីឆ្នាំ២០០៩តទៅ ។ និងជីសម្រាប់បង្កបង្កើនផលមានដូចជា ជីគីមី និងជីសរីរាង្គសុំឱ្យបញ្ចុះតម្លៃ ៣០% នៃតម្លៃបច្ចុប្បន្ន និងមានគុណភាពល្អ ទូទាំង ១០ស្រុកក្នុងខេត្តតាកែវ ចាប់ពីខែ កក្កដា ឆ្នាំ ២០០៩។ |
| ៣) សុំឱ្យស្តារប្រឡាយទឹកប្រវែង ១៥គីឡូម៉ែត្រ ក្នុងភូមិតាយឹង ឃុំដូងខ្ពស់ ស្រុកបូរីជលសា ចាប់ធ្វើពី ថ្នល់ ដល់ប្រឡាយ លេខ ០១ និងធ្វើអោយរួចនៅឆ្នាំ ២០១១ និងសុំឱ្យជីកប្រលាយទឹក នៅឃុំក្រាំងលាវ ស្រុកបាទី ដែលមានប្រវែង ៣ គីឡូម៉ែត្រ និងមុខកាត់មានប្រវែង ៤ ម៉ែត្រ សូមធ្វើឱ្យរួចរាល់នៅខែ មិថុនា ឆ្នាំ ២០១០ ។ |
| ៤) សុំឱ្យរដ្ឋសភាអនុម័តច្បាប់ប្រឆាំងអំពើពុករលួយក្នុងឆ្នាំ ២០១០ អោយបាន ។ |
| ៥) សុំជួយបង្កើនតម្លៃផលិតផលកសិកម្ម ស្រូវ ឱ្យបានមួយភាគបី នៃតម្លៃប្រេងសាំងក្នុងមួយលីត្រ ក្នុងស្រូវ១គីឡូក្រាម នៅក្នុង ខេត្តតាកែវ ចាប់ពីខែ សីហា ឆ្នាំ ២០០៩។ |
| ៦) សុំឱ្យពេទ្យសត្វមានកម្មវិធីចុះចាក់ថ្នាំបង្ការអោយបាន២ដងក្នុង១ឆ្នាំ អោយបានទៀងទាត់ទៅតាមប្រភេទសត្វ មាន គោ ក្របី មាន់ ទា ជ្រូក ... នៅទូទាំង១០ស្រុក ក្នុងខេត្តតាកែវ ចាប់ពីខែកក្កដា ឆ្នាំ២០០៩ តទៅ។ |
| ៧) សុំឱ្យតភ្ជាប់ប្រព័ន្ធសារទូរគមនាគមន៍ ICT និង បង្កើតវគ្គបង្រៀនខ្លីៗអំពីបច្ចេកវិទ្យាព័ត៌មាន នៅតាមវិទ្យាល័យទូទាំង ១០ស្រុក ក្នុងខេត្តតាកែវ ចាប់ពីឆ្នាំ២០១០ ។ |
| ៨) សុំអោយរដ្ឋាភិបាលបង្កើតសកលវិទ្យាល័យរដ្ឋមួយនៅខេត្តតាកែវ ហើយផ្តល់អាហារូបករណ៍យ៉ាង ហោចណាស់ ៧០ ភាគរយ សិស្សប្រលងជាប់ទី ១២ ក្នុងខេត្ត សុំអោយបានក្នុងឆ្នាំ២០១១ ។ |
| ៩) សុំឱ្យមានការបណ្តុះបណ្តាលវិជ្ជាជីវៈផ្នែកច្បាប់ និងជំនាញ [ទាក់ទងការងារ ]ដល់កងកំលាំងប្រដាប់អាវុធចាប់ពីឆ្នាំ ២០១០ នេះទៅ។ |
| ១០) សុំតប្រព័ន្ធទឹកស្អាត និងបញ្ចុះតម្លៃប្រើប្រាស់ ១០០០រៀល ក្នុង១ម៉ែត្រគូប នៅក្រុងដូនកែវ ចាប់ពីឆ្នោំ ២០០៩ ឱ្យហើយនៅឆ្នាំ ២០១០។ |

សិក្ខាសាលានេះត្រូវបានរៀបចំដោយគណៈកម្មាធិការខុមហ្វ្រែល សហការជាមួយសមាគមការពារសិទ្ធមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា (ADHOC) អង្គការពន្លឺសង្គម (BSO) សមាគមយុវជនខ្មែរ (KYA) ក្រុមប្រឹក្សាយុវជនកម្ពុជា (YCC) ដែលក្នុងនោះមានការចូលរួមពីម្ចាស់ឆ្នោត ដែលតំណាងអោយអង្គការមិនមែនរដ្ឋាភិបាលនានា អាជីវករ/ពាណិជ្ជករ មន្ត្រីរាជការ សិស្ស/ និស្សិត កសិករ មកពីស្រុកអង្គរបុរី ស្រុកគីរីវង្ស ស្រុកត្រាំកក់ ស្រុកទ្រាំង ស្រុកបុរីជលសា ស្រុកព្រៃកប្បាស ស្រុកបាទី ស្រុកសំរោង ស្រុកកោះអណ្តែត និង ក្រុងដូនកែវ នៅក្នុងខេត្តតាកែវ ។

សិក្ខាសាលាម្ចាស់ឆ្នោតនេះ ជាគំនិតបង្កើតថ្មីមួយក្នុងគោលបំណងឱ្យប្រជាពលរដ្ឋដែលជាម្ចាស់ឆ្នោតនៅតាមមណ្ឌលនីមួយៗ:

១) មានការយល់ដឹងពីកម្មវិធីនយោបាយនិងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលជាប់ឆ្នោតឆ្នាំ ២០០៨

២) ចូលរួមក្នុងការកំណត់លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពនានា ដែលត្រូវការចាំបាច់ក្នុងមណ្ឌល (ខេត្ត) របស់ខ្លួន

៣) និង លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពនានាសម្រាប់មណ្ឌលនីមួយៗ ត្រូវបានចងក្រងជារបាយការណ៍ដែលអាចឱ្យសិក្ខាកាមងាយចងចាំដើម្បីចូលរួមតាមដាន និងជម្រុញការអនុវត្តរបស់រាជរដ្ឋាភិបាល អ្នកតំណាងរាស្ត្រ ក្រុមប្រឹក្សា/គណៈអភិបាលខេត្ត-រាជធានី ក្នុងការសម្រេចបានលក្ខខណ្ឌសន្ទស្សន៍នៃវិស័យ ទាំងនោះ។


*សម្រាប់ព័ត៌មានបន្ថែមៗសូមទាក់ទង:*

- លោក **គឹម ឈុន** អ្នកសម្របសម្រួលជាន់ខ្ពស់នៃកម្មវិធីខុមហ្វ្រែល ទូរស័ព្ទ: ០១២ ៩៤២ ០១៩
- លោក **សុខ ពិន្ទុរឿ** អ្នកសម្របសម្រួលផ្នែកអង្កេតខុមហ្វ្រែល ទូរស័ព្ទ: ០៨៩ ៥២៥ ៤៨៦